ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
FAX/PHONE: (855) 23 427798
លេខ ២០៥......ប្រក.សហវ.ពដ

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០០

# ប្រកាស

## ស្តីពីការអនុវត្តន៍អាករលើតំលៃបន្ថែមចំពោះ
## ការផ្គត់ផ្គង់ថាមពលអគ្គិសនី

### ទេសរដ្ឋមន្ត្រី
### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលត្រូវបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦
- បានឃើញច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧
- បានឃើញអនុក្រឹត្យស្តីពីអាករលើតំលៃបន្ថែមលេខ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩
- ប្រកាសរួម លេខ ៦៩៦ ឧសក.រថ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

## <u>សំរេច</u> :

**ប្រការ ១ .-**

អាករលើតម្លៃបន្ថែម អនុវត្តចំពោះសហគ្រាសផលិតនិងផ្គត់ផ្គង់ថាមពលអគ្គិសនី ត្រូវបានកំណត់ដូចតទៅ :

១. ការផ្គត់ផ្គង់ថាមពលអគ្គិសនី ត្រូវបានចាត់ទុកថាជាការផ្គត់ផ្គង់មិនជាប់អាករ ។

២. ការផ្គត់ផ្គង់ទំនិញឬសេវាក្រៅពីថាមពលអគ្គិសនីត្រូវជាប់អាករតាមអត្រា ១០% ។

**ប្រការ ២ .-**

ឥណទានអាករលើធាតុចូលលើ ការនាំចូល ឬការទិញក្នុងស្រុក នូវសម្ភារៈនិងវត្ថុធាតុដើមសម្រាប់ផលិតនិងចែកចាយថាមពលអគ្គិសនី ត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិនៃ មាត្រា២៩ ដល់ មាត្រា៤១ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម ។

**ប្រការ ៣ .-**

អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានពន្ធដារ ប្រធាននាយកដ្ឋានទាំងអស់ចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសហគ្រាសដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

<u>ចម្លងជូន</u> :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- កាលប្បវត្តិ-ឯកសារ ។